ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ៧/២៣ ៧.ស /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៦

## សូមគោរពជូន
## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប

**កម្មវត្ថុ:** ការរៀបចំតាក់តែងកម្មវិធីផ្តល់ហិរញ្ញប្បទានថ្មីរបស់សហភាពអឺរ៉ុបដើម្បីបន្តគាំទ្រការអនុវត្តកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបថា ផ្អែកតាមកម្មវិធីប៉ាន់ស្មានហិរញ្ញប្បទានជំនួយពហុឆ្នាំ(២០១៤-២០២០)របស់សហភាពអឺរ៉ុបជួយរាជរដ្ឋាភិបាលកម្ពុជាលើគ្រប់វិស័យដែលមានថវិកាសរុបចំនួនប្រមាណ៤០០លានអឺរ៉ូ សហភាពអឺរ៉ុបបានគ្រោងផ្តល់ហិរញ្ញប្បទានចំនួនប្រមាណ៥០លានអឺរ៉ូ (ប្រមាណ៥៧លានដុល្លារអាមេរិក) សម្រាប់បន្តគាំទ្រដល់កម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិចាប់ពីឆ្នាំ២០១៧ដល់ឆ្នាំ២០២០។

ផ្អែកលើកិច្ចដំណើរការរៀបចំកម្មវិធីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប បាននិងកំពុងសហការជាមួយក្រុមការងារបច្ចេកទេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសហភាពអឺរ៉ុបក្នុងការកំណត់អំពី **១.) សមាភាគ ២.) ថេរវេលា** និង **៣.) ការបែងចែកហិរញ្ញប្បទានសម្រាប់សមាសភាគនីមួយៗនៃកម្មវិធីនេះ** ស្របទៅនឹងស្ថានភាពវិវត្តន៍ជាក់ស្តែងនៃកិច្ចដំណើរការកំណែទម្រង់ និងដើម្បីធានាដល់ការទទួលបានជំនួយហិរញ្ញប្បទាននេះចាប់ពីឆ្នាំ២០១៧តទៅ។

ផ្អែកលើការពិភាក្សាជាបន្តបន្ទាប់របស់ក្រុមការងារបច្ចេកទេស លេខាធិការដ្ឋានគ.ជ.អ.ប សូមគោរពរាយការណ៍ជូន**សម្តេចក្រឡាហោម** មេត្តាជ្រាបអំពីចំណុចសំខាន់ៗនៃការរៀបចំកម្មវិធីដែលបានឯកភាពគ្នាដូចខាងក្រោម៖

### I. សេចក្តីព្រាងឯកសារកម្មវិធី

#### ១. អំពីថេរវេលានៃកម្មវិធី៖

ទោះបីកម្មវិធីប៉ាន់ស្មានហិរញ្ញប្បទានពហុឆ្នាំដែលគាំទ្រពីសហភាពអឺរ៉ុបគ្របដណ្តប់លើថេរវេលារហូតត្រឹមឆ្នាំ២០២០ក៏ដោយ ក៏ដើម្បីធានាដល់ការរៀបចំកម្មវិធីប៉ានស្មានពហុឆ្នាំថ្មី(២០២០- ២០២៨) ក្រុមការងារបច្ចេកទេសបានឯកភាពគ្នាលើការបែងចែកកម្មវិធីគាំទ្រចំពោះមុខជា២ដំណាក់កាលដូចខាងក្រោម៖

- ដំណាក់កាលទី១ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០

- ដំណាក់កាលទី២ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២១

ការរៀបចំឱ្យមានដំណាក់កាលទី២រយៈពេល១ឆ្នាំ (២០២១) មានគោលបំណងដើម្បីធានាដល់ការតភ្ជាប់(អន្តរកាល)នូវការគាំទ្ររបស់សហភាពអឺរ៉ុបសម្រាប់ឆ្នាំ២០២១ ក្នុងករណីដែលការរៀបចំកម្មវិធីប៉ាន់ស្មានហិរញ្ញប្បទានជំនួយពហុឆ្នាំដំណាក់កាលបន្ទាប់មានភាពយឺតយ៉ាវក្នុងការអនុម័តដូចធ្លាប់បានកើតឡើងនៅក្នុងដំណាក់កាលទី១នាពេលកន្លងមកនេះ (កម្មវិធីបច្ចុប្បន្ននេះមានថេរវេលាគ្របដណ្តប់ពីឆ្នាំ២០១៤ដល់ឆ្នាំ២០២០ ប៉ុន្តែទើបតែបានចុះហត្ថលេខាជាមួយគ្នានៅចុងឆ្នាំ២០១៥)។

**២. អំពីសមាសភាគនានានៃកម្មវិធីដំណាក់កាលទី១៖**

សមាសភាគដែលបានគ្រោងសម្រាប់កម្មវិធីនេះមានចំនួន៣៖

ក. ការគាំទ្រសកម្មភាពស្នូលនៃកម្មវិធីកំណែទម្រង់

ខ. ការគាំទ្រមូលនិធិក្រុង ស្រុក និង

គ. ការគាំទ្រក្នុងលក្ខណៈជាវិធានការបំពេញបន្ថែម (គ្រប់គ្រងដោយសហភាពអឺរ៉ុបផ្ទាល់)

**៣. អំពីការគ្រោងថវិកាសម្រាប់កម្មវិធី និងសមាសភាគនីមួយៗនៃកម្មវិធី**

ផ្អែកលើការបែងចែកជាដំណាក់កាល និងសមាសភាគសំខាន់ៗនៃកម្មវិធីដូចបានគូសបញ្ជាក់ខាងលើ ក្រុមការងារបច្ចេកទេសបានស្នើគ្រោងថវិកាសម្រាប់កម្មវិធីទាំងពីរដំណាក់កាលដូចខាងក្រោម៖

- កម្មវិធីដំណាក់កាលទី១ (២០១៧-២០២០) មានចំនួន**៤៧លាន**ដុល្លារអាមេរិក
- កម្មវិធីដំណាក់កាលទី២ (២០២០-២០២១) មានចំនួន**១០លាន**ដុល្លារអាមេរិក

ថវិកា**៤៧លានដុល្លារ** នៃកម្មវិធីដំណាក់កាលទី១ ត្រូវបានគ្រោងបែងចែកសម្រាប់សមាសភាគនីមួយៗនៃកម្មវិធីដូចខាងក្រោម៖

- ✓ ការគាំទ្រសកម្មភាពស្នូលនៃកំណែទម្រង់ចំនួន**២៩លានដុល្លារ**
- ✓ ការគាំទ្រមូលនិធិក្រុង ស្រុកចំនួន**១២លានដុល្លារ**
- ✓ ការគាំទ្រក្នុងលក្ខណៈជាវិធានការបំពេញបន្ថែមចំនួន**៦លានដុល្លារ**

## II.វិធីសាស្ត្រនៃការផ្តល់ហិរញ្ញប្បទាន និងប្រលេក្ខខណ្ឌនានារបស់សហភាពអឺរ៉ុប៖

### ១.អំពីវិធីសាស្ត្រនៃការផ្តល់ហិរញ្ញប្បទាន

ជារួម ការផ្តល់ហិរញ្ញប្បទានរបស់សហភាពអឺរ៉ុបចំពោះគម្រោង និងកម្មវិធីលើគ្រប់វិស័យនានានៅកម្ពុជាត្រូវបានទីចាត់ការកណ្តាលរបស់សហភាពអឺរ៉ុបសម្រេចជាគោលការណ៍ថា នឹងត្រូវចាប់ផ្តើមអនុវត្តតាមបែបផែនជា "**ការគាំទ្រថវិកា**" ឬហៅថា "**ការទ្រទ្រង់ថវិកា**" (Budget Support)។ តាមបែបផែននេះ ការផ្តល់ហិរញ្ញប្បទានរបស់សហភាពអឺរ៉ុបចំពោះកំណែទម្រង់ចាប់ពីឆ្នាំ២០១៧តទៅនឹងត្រូវបានផ្លាស់ប្តូរពីបែបផែន "**កម្មវិធីប៉ាន់ស្មាន**" (Program Estimated-PE) ដែលធ្លាប់បានប្រើប្រាស់ក្នុងការគាំទ្រកំណែទម្រង់កន្លងមកទៅជាបែបផែន"**ការគាំទ្រថវិកា**"វិញ។ តាមបែបផែននៃ**ការគាំទ្រថវិកា**នេះ សហភាពអឺរ៉ុប

នឹងផ្តល់ថវិកាទៅឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបន្តផ្ទេរមកឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប ពោលគឺមិនត្រូវបានផ្ទេរត្រង់មកលេខាធិការដ្ឋានគ.ជ.អ.ប ដូចធ្លាប់បានអនុវត្តមកទល់បច្ចុប្បន្ននេះទេ។

---

**២.អំពីបុរេលក្ខខណ្ឌនានារបស់សហភាពអឺរ៉ុប**

ទោះបីបែបផែននៃការគាំទ្រថវិកាធ្លាប់បានអនុវត្តខ្លះៗនៅក្នុងការផ្តល់ហិរញ្ញប្បទានគាំទ្រពីដៃគូអភិវឌ្ឍន៍ទៅលើគម្រោងមួយចំនួននៅកម្ពុជា ហើយវាក៏ជាបែបផែនមួយដែលអាចជួយពង្រឹងបន្ថែមទៀតដល់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏ពិតមែន ក៏ប៉ុន្តែបែបផែននេះនៅមិនទាន់ត្រូវបានអនុវត្តពេញលេញ និងមានភាពរលូននៅឡើយ។ ក្នុងបែបផែននេះ ឯកសារគម្រោងកម្មវិធីតម្រូវឱ្យមានការកំណត់អំពីសូចនាករចំនួនប្រមាណ១០ដែលមានលក្ខណៈសមស្រប អាចអនុវត្ត និងវាស់វែងបាន ព្រមទាំងត្រូវមានការឯកភាពគ្នាជាមុនពីភាគីទាំងសងខាង។

ជាមួយគ្នានឹងការផ្លាស់ប្តូរនូវបែបផែននៃការផ្តល់ហិរញ្ញប្បទានបែបថ្មីដែលខ្លួនក៏យល់ឃើញផងដែរថានឹងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនក្នុងបណ្តាឆ្នាំដំបូងៗនោះ សហភាពអឺរ៉ុបបានកំណត់នូវលក្ខខណ្ឌមួយចំនួនដែលតម្រូវឱ្យមានការសម្រេចចិត្តពីរាជរដ្ឋាភិបាលមុនការផ្តល់ការឯកភាពពីសហភាពអឺរ៉ុបទៅលើការផ្តល់ហិរញ្ញប្បទានដល់កម្មវិធីនេះ។ បុរេលក្ខខណ្ឌទាំងនោះរួមមាន៖

**ទីមួយ៖** ការរៀបចំឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប ក្លាយជា**អង្គភាពថវិកា**

**ទីពីរ៖** ដោយសារការផ្តល់ហិរញ្ញប្បទានពីសហភាពអឺរ៉ុបសម្រាប់ឆ្នាំដំបូង(២០១៧)នៃកម្មវិធីនឹងអាចផ្តល់ឱ្យនៅម៉ឺខែមេសា អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលត្រូវមានការយល់ព្រមក្នុងការផ្តល់ថវិការបស់រដ្ឋជាមុនសិនសម្រាប់ការចំណាយរបស់កម្មវិធីពីដើមឆ្នាំរហូតដល់ម៉ឺខែមេសា ដែលជាពេលវេលារំពឹងថាសហភាពអឺរ៉ុបនឹងផ្ទេរថវិកាប្រចាំឆ្នាំក្នុងបែបផែនជា "**កញ្ចប់ជាក់លាក់**" (Fix Tranche)មកឲ្យរដ្ឋ។ ដោយឡែក ចាប់ពីឆ្នាំទី២នៃកម្មវិធីតទៅ រាជរដ្ឋាភិបាលត្រូវចំណាយថវិការបស់ខ្លួនជាមុនសិនរហូតដល់ម៉ឺខែសីហា ទើបសហភាពអឺរ៉ុបអាចផ្ទេរថវិការបស់ខ្លួនក្នុងបែបផែនជាការផ្ទេរដោយផ្អែកតាមការវាស់វែងលើលទ្ធផលនៃការអនុវត្ត សូចនាករនីមួយៗ (Variable Tranche)។ ក្នុងបែបផែននេះ ប្រសិនបើសូចនាករណាមួយមិនត្រូវបានអនុវត្ត ឬអនុវត្តបានក្នុងអត្រាភាគរយណាមួយនោះ នោះសហភាពអឺរ៉ុបនឹងមិនផ្តល់ថវិកា ឬផ្តល់ថវិកាទៅតាមអត្រា ភាគរយដែលបានសម្រេចទៅលើសូចនាករនោះតែប៉ុណ្ណោះ។

**ទីបី៖** ការបង្កើនធនធានធន្ទានុសិទ្ធិរបស់រដ្ឋបាលក្រុង ស្រុក (មូលនិធិក្រុង ស្រុក)

គោលបំណងដែលស្នើឱ្យមានការគាំទ្រពីសហភាពអឺរ៉ុបទៅលើមូលនិធិក្រុង ស្រុក(ចំនួន១២លានដុល្លារសម្រាប់តែឆ្នាំ២០១៧ និងឆ្នាំ២០១៨) គឺដើម្បីធានាឱ្យក្រុង ស្រុកនីមួយៗមានថវិកាកើនឡើងសមស្របសម្រាប់ការអភិវឌ្ឍន៍មូលដ្ឋានចាប់ពីឆ្នាំ២០១៧តទៅរហូតដល់ចំនួនថវិកានេះអាចធានារ៉ាប់រងបានដោយផ្ទាល់ពីរាជរដ្ឋាភិបាលនៅឆ្នាំ២០១៩ អាស្រ័យហេតុនេះ សហភាពអឺរ៉ុបបានស្នើសុំឱ្យមានការពិនិត្យកែសម្រួលឡើងវិញនូវអនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋទៅឱ្យមូលនិធិក្រុង ស្រុក (សំខាន់ពាក់ព័ន្ធទៅនឹងរូបមន្តបែងចែក និងអត្រាភាគរយនៃមូលនិធិក្រុង ស្រុកនៅឆ្នាំ២០១៩)។

លក្ខខណ្ឌទាំងបីខាងលើនេះ គឺជាបុរេលក្ខខណ្ឌរបស់សហភាពអឺរ៉ុបក្នុងការអនុម័តលើការផ្តល់ហិរញ្ញប្បទានដល់កម្មវិធី។

## III. សំណើសុំគោលការណ៍ដឹកនាំលើបញ្ហាសំខាន់ៗមួយចំនួន

ជារួម នៅក្នុងការអនុវត្តកម្មវិធីកំណែទម្រង់មកទល់បច្ចុប្បន្ននេះ ប្រសិទ្ធភាពនៃការសម្របសម្រួលការអនុវត្តកម្មវិធីកំណែទម្រង់ជាទូទៅ ផ្អែកជាសំខាន់ទៅលើប្រព័ន្ធផ្តល់ថវិកាពីដៃគូអភិវឌ្ឍន៍ដែលគាំទ្រជាសំខាន់ទៅលើកិច្ចប្រតិបត្តិការនៃកម្មវិធីកំណែទម្រង់នៅទូទាំងប្រទេស(ការអភិវឌ្ឍន៍គោលនយោបាយ ការអភិវឌ្ឍន៍សមត្ថភាព ការផ្តល់នូវសំភារៈមធ្យោបាយជាមូលដ្ឋាន និងការផ្តល់ជំនួយបច្ចេកទេសដល់ស្ថាប័នអនុវត្តនានា រួមមាន ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ)។ ថវិកាទាំងនោះធ្លាប់ត្រូវបានផ្តល់មកឱ្យ គ.ជ.អ.ប តាមការកំណត់ និងទាន់ពេលវេលា ដោយផ្អែកតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដែលបានអនុម័តដោយគ.ជ.អ.ប។ ផ្អែកលើថវិកានេះ លេខាធិការដ្ឋាន គ.ជ.អ.ប ក៏បានបន្តបែងចែក និងផ្ទេរទៅឱ្យស្ថាប័នអនុវត្តនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិយ៉ាងទាន់ពេលវេលា ផ្អែកតាមសេចក្តីសម្រេចរួមដែលបានឯកភាព និងចុះហត្ថលេខារវាង គ.ជ.អ.ប និងស្ថាប័នអនុវត្តនីមួយៗ។

ជាការពិតណាស់ សហភាពអឺរ៉ុបនឹងក្លាយជាដៃគូដ៏សំខាន់ជាងគេចាប់ពីឆ្នាំ២០១៧តទៅក្នុងការផ្តល់ហិរញ្ញប្បទានគាំទ្រដល់កំណែទម្រង់ក្នុងពេលដែលដៃគូដទៃទៀតកំពុងកាត់បន្ថយនូវជំនួយគាំទ្ររបស់ខ្លួនជាបណ្តើរៗ។ ផ្អែកលើលក្ខណៈស្មុគ្រស្មាញ និងបញ្ហាប្រឈមនានា កិច្ចដំណើរការកំណែទម្រង់គឺពិតជានៅត្រូវការជាចាំបាច់នូវការគាំទ្រពីដៃគូអភិវឌ្ឍន៍ទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសក្នុងរយៈពេលមធ្យមមួយបន្ថែមទៀត។

ផ្អែកលើស្ថានភាពខាងលើនេះ ព្រមជាមួយគ្នានឹងការផ្លាស់ប្តូរនូវបែបផែននៃការផ្តល់ហិរញ្ញប្បទានរបស់សហភាពអឺរ៉ុប លេខាធិការដ្ឋាន គ.ជ.អ.ប និងមន្ត្រីបច្ចេកទេសរបស់សហភាពអឺរ៉ុបកំពុងមានការព្រួយបារម្ភទៅលើប្រព័ន្ធបង្ហូរថវិកាបែបថ្មី (តាមប្រព័ន្ធថវិការបស់រាជរដ្ឋាភិបាល) ចាប់ពីឆ្នាំ២០១៧តទៅក្នុងការគាំទ្រដល់កិច្ចដំណើរការជាទូទៅនៃកំណែទម្រង់ដែលអាចមានលក្ខណៈយឺតយ៉ាវ និងធ្វើឱ្យប៉ះពាល់ដល់ការសម្រេចបាននូវសូចនាករនានាដែលបានកំណត់តាមពេលវេលាយ៉ាងច្បាស់លាស់។

ដើម្បីធានាប្រសិទ្ធភាពនៃការបន្តដឹកនាំ និងសម្របសម្រួលការអនុវត្តកម្មវិធីកំណែទម្រង់ក្នុងបែបផែននៃការផ្លាស់ប្តូរការផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ លេខាធិការដ្ឋាន គ.ជ.អ.ប សូមគោរពស្នើសុំ **សម្តេចក្រឡាហោម** មេត្តាពិនិត្យ និងសម្រេចលើចំណុចសំខាន់ៗដូចខាងក្រោម៖

**ទីមួយ៖** ស្នើសុំការពិនិត្យ និងសម្រេចទៅលើចំណុចសំខាន់ៗ(ថេរវេលា សមាសភាគនានា និងការបែងចែកថវិកា)នៃការរៀបចំឯកសារកម្មវិធីដូចបានគោរពរាយការណ៍ក្នុងចំណុចទី I

**ទីពីរ៖** ស្នើសុំរៀបចំលិខិតពី គ.ជ.អ.ប ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីស្នើសុំ៖

- ✓ កំណត់ឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប ក្លាយជាអង្គភាពថវិកា

- ✓ រៀបចំ និងផ្ទេរថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមកលេខាធិការដ្ឋាន គ.ជ.អ.ប ផ្អែកតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដែលបានអនុម័តដោយគ.ជ.អ.ប
- ✓ កែសម្រួលអនុក្រឹត្យលេខ៣៤២ អនក្រ.បក ស្តីពីការចូលរួមធនធានពីថវិកាជាតិដល់មូលនិធិក្រុង ស្រុក ដើម្បីបង្កើនថវិកាធនធានុសិទ្ធិរបស់រដ្ឋបាលក្រុង ស្រុកចាប់ពីឆ្នាំ២០១៩តទៅ។
- ✓ អនុញ្ញាតឱ្យប្រើប្រាស់ថវិការដ្ឋជាមុន មុននឹងទទួលបានការផ្ទេរថវិកាពីសហភាពអឺរ៉ុប ដើម្បីទូទាត់ថវិការដ្ឋដែលបានប្រើប្រាស់រួច។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**